**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៣៤០
ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៩
**សាលដីកា**
លេខ:២៤២
ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ................ ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ................. ជាចៅក្រមរបាយការណ៍
៥-លោក ............. ជាចៅក្រម
៦-លោក ........... ជាចៅក្រម
៧-លោក ............ ជាចៅក្រម
៨-លោក ................ ជាចៅក្រម
៩-លោក ............ ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោកស្រី ..........។

**<u>តំណាងមហាអយ្យការ</u>**

-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៤៩៩ ចុះថ្ងៃទី២៧-០៧-១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៩ ចុះថ្ងៃទី២៩-០៦-៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះហវ ភេទប្រុសអាយុ៤៩ឆ្នាំ ជាតិខ្មែរ របររកស៊ីជាងដែក ទីលំនៅសព្វថ្ងៃ ផ្ទះលេខ៣៤២C សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ឪពុកឈ្មោះសូ ហ៊ួ(ស) ម្តាយឈ្មោះហេង ឆាយ (រ) ។

និងចុងបណ្តឹងសាទុក្ខឈ្មោះបធវ ភេទប្រុស អាយុ៣៦ឆ្នាំ របររកស៊ីអាកាសយានិកទព័អកាស ទីលំនៅសព្វថ្ងៃផ្ទះលេខ៣៤២D ផ្លូវលេខ១៨២ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ប្រាក់ ផន (ស) ម្តាយឈ្មោះចាន់ នី (ស) ។

**<u>កម្មវត្ថុបណ្តឹង:</u>**ប្តឹងទាមទារឲ្យគោរពកិច្ចសន្យាសំណង់ ។

តាមបណ្តឹងសាទុក្ខលើកទី២លេខ២៦១ ចុះថ្ងៃទី២៩-០៧-៩៩ របស់ឈ្មោះហវ ប្តឹងមិនសុខចិត្ត ពីសាលដីកាលេខ៤៩ ចុះថ្ងៃទី២៧-០៧-៩៩ របស់សាលាឧទ្ធរណ៍លើចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៤០ ចុះថ្ងៃទី២៩-១០-១៩៩៩ របស់តុលាការកំពូល ។ តាមពាក្យបណ្តឹង របស់ដើមចោទឈ្មោះបធវ ចុះថ្ងៃទី០៨-០៣-៩៣ ប្តឹងពីឈ្មោះហវ ម្ចាស់ម៉ៅការសំណង់ ដែលបានសាងសង់ផ្ទះហួសពេលកំណត់ នៅក្នុងកុងត្រា ជាមួយគ្នា ការសាងសង់ ហើយបែងចែកមិនសមស្រប ដោយពីល្វែងរបស់ខ្លួន បានរៀបចំ និងលំអរបានស្អាតបាត ជាង២ល្វែងដែលចែក ឱ្យខ្លួន ។

បានឃើញសាលក្រមលេខ២១(គ) ចុះថ្ងៃទី១៤-០២-៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣ របស់ដើមចោទឈ្មោះបធវន៍ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បង្គាប់ឱ្យឈ្មោះហវ ដាក់សំភារៈបន្ថែមនៅផ្ទះល្វែងខាងបធវន៍ គ្រប់គ្រងផ្ទះលេខ៣៤២D ផ្លូវ១៨២ ក្រុម២៨ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ គឺត្រូវដាក់សង្កសីទ្វារដែក ផ្នែកខាងក្រោយ ជាន់ផ្ទាល់ដី ដាក់បំពង់ផ្សែងចង្ក្រានបាយចេញក្រៅផ្ទះ ធ្វើបង្អួចខាងមុខ នៅជាន់អីអង រៀបឥដ្ឋជើងជញ្ជាំង ធ្វើទ្វាដែកឡើងវិញ ធ្វើសោរបិទបើក និងជួសជុលផ្នែកសំណង់ផ្ទះល្វែងលេខ៣៤២A ៣៤២ D ឱ្យបានត្រឹមត្រូវតាមលក្ខ័ណសំណង់វិញ មានធ្នឹមជាន់លើរហូតជាន់ផ្ទាល់ដី. ពិដានជាន់អីអងផ្នែកខាងមុខ អាង ទឹកលើដំបូល អាងទឹកបន្ទប់ក្រោម បន្ទប់ទឹកជាន់ទី១ ជួសជុលផ្នែកបណ្តោញទឹក ។ ហើយក្នុងការជួសជុល ត្រូវជានាការប្រេស្រធាំចំនួន១០ឆ្នាំ និងការបាក់ស្រុត២០ឆ្នាំ តាមកិច្ចសន្យានៅសំណង់ខណ្ឌទួលគោក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ១៩៩៣ ។

-ករណីរឹងទទឹងមិនព្រមជួសជុល និងដាក់សំភារៈបន្ថែម ត្រូវរឹបអូសផ្ទះល្វែងរបស់ឈ្មោះហូ វ៉ាន់ គ្រប់គ្រងផ្ទះលេខ៣៤២សេ ផ្លូវ១៨២ ក្រុម២៨ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ លក់យកប្រាក់ ដើម្បីធ្វើការជួសជុល និងទិញសំភារៈដាក់ផ្ទះលេខ ៣៤២D និង ៣៤២A វិញ ។

៣-បង្គាប់ឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តី មានពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៣០០០រៀល រង្វាន់សាក្សី២០០០រៀល បូករួម ៧០០០រៀល ដែលដើមចោទបង់ទុកជាស្រេច ។

-កាលបើហួសឧទ្ធរណ៍ហើយ បង្គាប់ឱ្យចុងចម្លើយសងប្រាក់៧.០០០រៀល ទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ ជាប្រាក់មួយភាគរយលើតម្លៃជួសជុលផ្ទះ ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ៨០ភាគរយ និង រង្វាន់ក្រឡាបញ្ជីទូទាំងព្រះរាជាណាចក្រកម្ពុជា ២០ភាគរយ តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៤-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូភាគី បើកផ្លូវឧទ្ធរណ៍ រយៈពេល២ខែ ចាប់ពីថ្ងៃនេះទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះហវ ចុះថ្ងៃទី១៧-០២-៩៧ ប្តឹងមិនសុខចិត្តលើសេចក្តីសម្រេច នៃសាលក្រមទាំងមូល ។

បានឃើញសាលដីកា របស់សាលាឧទ្ធរណ៍លេខ៥៧៦ ចុះថ្ងៃទី២៥-០៩-៩៧ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៧-០២-៨៧ របស់ឈ្មោះហួ វ៉ាន់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២១(គ) ចុះថ្ងៃទី១២-០២-៩៧ របស់តុលាការក្រុង ភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០ រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និង អាជ្ញាធរតុលាការ ៥.០០០រៀល សរុបចំនួន ១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុង កំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខរបស់ឈ្មោះហវ លេខ៤១៩ ចុះថ្ងៃទី០៥-១១-៩៧ ប្តឹងមិនសុខចិត្ត លើសេចក្តីសម្រេច នៃសាលដីកាទាំងមូល ។

បានឃើញសាលដីកា របស់តុលាការកំពូលលេខ១០៦ ចុះថ្ងៃទី២៨-០៤-៩៨ ដែលមាន ខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ៤១៩ ចុះថ្ងៃទី០៥-១១-៩៧ របស់លោកហួ វ៉ាន់ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៥៧៦ ចុះថ្ងៃទី២៥-០៩-៩៧ របស់សាលាឧទ្ធរណ៍

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ០៧ ចុះថ្ងៃទី០៨-០១-៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលភាគីលោកបធវន៍ បានបង់ជួសចំនួន ១៩.០០០រៀល គឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន១៥.០០០រៀល សរុប១៩០០០រៀល ។

៥-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៨ ។

បានឃើញសាលដីកា របស់សាលាឧទ្ធរណ៍លេខ៤៩៩ ចុះថ្ងៃទី២៧-០៧-៩៩ ដែលមាន ខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលសំណុំរឿងរដ្ឋប្បវេណី លេខ២៩ ចុះថ្ងៃទី២៩-០៦-១៩៩៨ របស់សាលាឧទ្ធរណ៍ ជំនុំជំរះ ជាថ្មី តាមអំណាចសាលដីការដ្ឋប្បវេណីលេខ១០៦ ចុះថ្ងៃទី២៨-០៤-១៩៩៨ របស់តុលាការកំពូល ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២១(គ) ចុះថ្ងៃទី១៤-០២-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-សំណូមពរ របស់គូក្តីស៊ីលើកចោល តែទុកសិទ្ធិឱ្យប្តឹងទៅតុលាការថ្នាក់ក្រោម លើសំណង ជម្ងឺចិត្ត និងប្រាក់ក្រៅកិច្ចសន្យា ចាប់ពីសាលដីកានេះចូលជាស្ថាពរ .

៤-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍១៣.០០០រៀល ដែលដើមបណ្តឹងបានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់បឹបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ៥.០០០រៀល រង្វាន់អាជ្ញាធរតុលាការ ៥០០០រៀល ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខរយៈពេល ២ខែ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ២៦១ ចុះថ្ងៃទី២៩-០៧-៩៩ របស់ហវ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណា ចុះថ្ងៃទី០១-១២-៩៩ របស់ឈ្មោះហ៊ូ វ៉ាន់ ។

បានឃើញសារណាតប ចុះថ្ងៃទី២០-១២-៩៩ របស់ឈ្មោះ បធវ័ន ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា

-បណ្តឹងសាទុក្ខលើកទី២ របស់ឈ្មោះហវ ចុងចម្លើយធ្វើឡើងក្នុងកំណត់ច្បាប់គប្បីលើកយក មកពិនិត្យពិចារណា ។

-សាលដីការដ្ឋប្បវេណីលើកទី២លេខ៤៩៩ ចុះថ្ងៃទី២៧-០៧-៩៩ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គង ទាំងទម្រង់ ទាំងគតិច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចំម្លើយរបស់ឈ្មោះហវ ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះថាៈ

ការសាងសង់នេះ មានលក្ខណៈត្រឹមត្រូវ ដោយខ្លួនត្រូវប្រគល់លុយកក់ចំនួន៣តម្លឹង ឱ្យដើមចោទ ដើម្បីជានាការសាងសង់ តែក្នុងករណីខ្លួនសង់រួចតាមកិច្ចសន្យាដើមចោទ ត្រូវប្រគល់លុយកក់នោះមកឱ្យខ្លួនវិញ ។ តែដើមចោទឲ្យខ្លួនវិញតែ ១តម្លឹងកន្លះ នៅសល់១តម្លឹងកន្លះទៀត ដើមចោទមិនព្រមឱ្យដោយ យកលេសថា ខ្លួនសង់ផ្ទះមិនរួចតាមកិច្ចសន្យា តែការយឺតយ៉ាវនេះ មិនមែនបណ្តាលមកពីខ្លួនទេ

គឺបណ្ដាលមក ពីដើមចោទ មិនព្រមប្រគល់លុយតាមកិច្ចសន្យា ។ មិនតែប៉ុណ្ណោះគាត់ឱ្យខ្លួនធ្វើកម្មសិទ្ធិផ្ទះឱ្យទៀត ។

បានស្តាប់ចម្លើយរបស់ឈ្មោះបធរ ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះថា តាមកិច្ចសន្យាទី២ ក្នុងករណីឈ្មោះហរ សង់រួចត្រូវប្រគល់ប្រាក់កក់ចំនួន១តម្លឹងកន្លះទៀត តែឈ្មោះនេះមិនបានគោរពតាមកិច្ចសន្យានេះទេ គឺអាងទឹកប្រើមិនកើត ទ្វារមិនទាន់ដាក់ អំពូលភ្លើងក៏មិនទាន់ដាក់ មិនតែ ប៉ុណ្ណោះគាត់មិនបានបោសសំអាតកំបោរ ។ គាត់ឱ្យខ្លួនស្នាក់នៅបណ្តោះអាសន្ន ហើយគាត់សន្យាថាជួសជុលបន្តទៀត តែគាត់មិនបានបំពេញកាតព្វកិច្ចនេះទេ មិនតែប៉ុណ្ណោះគាត់មិនធ្វើប្លង់ឱ្យខ្ញុំទេ ដល់សួរគាត់ៗ ថាប្លង់នៅជាមួយប្អូនខ្ញុំ តែតាមពិតគាត់មិនបានធ្វើប្លង់ឱ្យខ្ញុំទេ ។ ចំពោះការដូរផ្ទះគ្នា បើគាត់សុំដូរក្នុងតំណាក់ការដំបូង ខ្ញុំសុខចិត្តដូរឱ្យ តែបើឈានចូលដល់តំណាក់ការនេះ ខ្ញុំមិនដូរទេ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ២៦១ ចុះថ្ងៃទី២៩-០៧-៩៩ របស់លោកហរ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ ដល់អង្គសេចក្តីបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សម្រេចតម្កល់សាលក្រមរដ្ឋប្បវេណីលេខ២១(គ) ចុះថ្ងៃទី១៤-០២-៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការនោះ គឺជាការភន្ត័ច្រឡំ ពីព្រោះថា :

-សាលក្រមនេះ ត្រូវបានសាលាឧទ្ធរណ៍ សម្រេចតម្កល់ទុកជាបានការ ម្តងមកហើយ តាមអំណាច សាលដីការដ្ឋប្បវេណីលេខ៥៧៦ ចុះថ្ងៃទី២៥-០៩-៩៧ ហើយសាលដីកានេះ ក៏ត្រូវបានតុលាការកំពូល សម្រេច ទុកជាមោឃៈរួចមកហើយដែរ តាមអំណាចសាលដីការដ្ឋប្បវេណីលេខ១០៦ ចុះថ្ងៃទី២៨-០៤-៩៨ ។

-ក្នុងករណី ដែលសាលាឧទ្ធរណ៍ យល់ឃើញថា សាលក្រមរដ្ឋប្បវេណីលេខ២១(គ) ចុះថ្ងៃទី១៤-០២-៩៧ របស់តុលាការក្រុងភ្នំពេញមានលក្ខណៈត្រឹមត្រូវនោះ ក៏សាលាឧទ្ធរណ៍ គប្បីសម្រេចជាថ្មីទៀតដែរ ។

-យល់ឃើញថាលោកហរ បានបំពេញកាតព្វកិច្ច តាមកិច្ចសន្យ ចុះថ្ងៃទី០៣-០៥-៩៣ នៅយុត្តិធម៌ឧទ្ទលគោករួចហើយ ប៉ុន្តែនៅពេលផ្សះផ្សា នៅតុលាការក្រុងភ្នំពេញ ថ្ងៃទី០១-០៧-៩៤ លោក

ហាវ សុខចិត្តសម្រួល ដោយសំណូមពរឱ្យច្បាស់ផ្ទះជួសជុលខ្លួនឯង ហើយខ្លួនមិនទាមទារប្រាក់កក់ទាំងអស់នោះទេ ម្យ៉ាងទៀត ដើមចោទ លោកបធវ័ ក៏បានចូលទៅនៅក្នុងផ្ទះដែលជាចំណែករបស់ខ្លួន ឯការជួសជួល និងប្រាក់កក់ ក៏មានតម្លៃសមាមាត្រនឹងគ្នាហើយដែរ ដែលតុលាការគប្បីពិចារណា ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤៩៩ ចុះថ្ងៃទី២៧-០៧-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេក្តី ចំពោះមុខគូភាគី**

១-ទទួលបណ្តឹងសាទុក្ខ លើកទី២លេខ២៦១ ចុះថ្ងៃទី២៩-០៧-៩៩ របស់លោកហាវ ទុកជាត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៤៩៩ ចុះថ្ងៃទី២៧-០៧-៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-ឱ្យគូភាគី រួចផុតពីកាតព្វកិច្ចរៀងៗខ្លួន ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន១៩.០០០រៀល ដែលលោកបធវ័ បានបង់រួចហើយ គឺៈ -ពន្ធចុះបញ្ជីក្តី និងពុទ្ធហ្មឹង ចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន១៥.០០០រៀល សរុប ១៩.០០០រៀល ។

៥-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០០ ។